**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ.០០៣..សសក

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០០៩..

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ជំរាបមក**

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ**

**កម្មវត្ថុ :** ករណីសំណើសុំកែសំរួលគោលការណ៍ណែនាំជាតិ ស្តីពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ លើកុមារ នៅប្រទេសកម្ពុជា នាខែវិច្ឆិកា ឆ្នាំ ២០០៧។

**យោង :** លិខិតលេខ ១៦១៦ មជអសក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបលោកប្រធានអោយបានជ្រាបថា ក្រសួងសុខាភិបាលអនុញ្ញាតិអោយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានសហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដើម្បីពិនិត្យ និងកែសំរួលឡើងវិញនូវលក្ខខ័ណ្ឌក្នុងការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ លើទារកអាយុក្រោម ១២ ខែ។ លទ្ធផលនៃកិច្ចប្រជុំបានឯកភាពទាំងស្រុង ទៅតាមអនុសាសន៍របស់អង្គការសុខភាពពិភពលោក ដោយសំរេចអោយចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដល់ទារក អាយុក្រោម១២ខែទាំងអស់ នៅពេលដែលលទ្ធផលតេស្តឈាមរកមេរោគអេដស៍ (PCR test) បញ្ជាក់ថាវិជ្ជមាន ដោយពុំចាំបាច់រង់ចាំលទ្ធផលនៃការពិនិត្យភាគរយនៃគ្រាប់ឈាម $CD_4$ ដើម្បីអាចកាត់បន្ថយអោយបានជាអតិបរមាអត្រាកើតជំងឺនិងអត្រាមរណៈរបស់ទារក ដែលបានឆ្លងមេរោគអេដស៍។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាប និងចាត់ចែងតាមការគួរ ។

សូមលោកប្រធានទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ម៉ម_ប៊ុនហេង**

ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល,លេខ ១៥១-១៥៣ វុក្មរិថី កម្ពុជាក្រោម ភ្នំពេញ ទូរសព្ទ-ទូរសារ: (៨៥៥-២៣) ៨២៦ ០៣៤/៨២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៩៣៣

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍
សើស្បែក និង កាមរោគ
លេខ...១២៣...មជសក

រាជធានីភ្នំពេញ, ថ្ងៃទី...៣០...ខែ..០១....ឆ្នាំ២០០៩

## ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

## ជំរាបជូន

## លោក/លោកស្រីប្រធានក្រុមថែទាំ-ព្យាបាលជំងឺអេដស៍

## លើកុមារ ទូទាំងប្រទេសកម្ពុជា

**កម្មវត្ថុ :** ការកែសំរួលគោលការណ៍ណែនាំជាតិ អំពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ លើកុមារ នៅប្រទេសកម្ពុជា ។

**យោង :** លិខិតអនុញ្ញាតិរបស់ក្រសួងសុខាភិបាល លេខ ០០៣ អបស ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបលោក/លោកស្រីប្រធានក្រុមថែទាំ-ព្យាបាលជំងឺអេដស៍ លើកុមារ អោយបានជ្រាបថា ក្រសួងសុខាភិបាលបានអនុញ្ញាតិអោយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ធ្វើការកែសំរួលឡើងវិញ នូវលក្ខខ័ណ្ឌក្នុងការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ លើទារកអាយុក្រោម ១២ ខែ ដោយសំរេចអោយចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ **ដល់ទារក អាយុក្រោម១២ខែទាំងអស់** នៅពេលដែលលទ្ធផល តេស្តឈាមរកមេរោគអេដស៍ (PCR test) បញ្ជាក់ថាវិជ្ជមាន **ដោយពុំចាំបាច់រង់ចាំលទ្ធផលនៃការពិនិត្យរោគសញ្ញា នៃគ្រាប់ឈាម** CD4 ដើម្បីអាចកាត់បន្ថយអោយបានជា អតិបរមានូវអត្រាកើតជំងឺនិងអត្រាមរណៈរបស់ទារកដែលបានឆ្លងមេរោគអេដស៍ ។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានជ្រាប និងចាត់ចែងអនុវត្តតាមសេចក្តីកែសំរួលនេះតាមការគួរ ។

សូមលោក/លោកស្រីប្រធានទទួលនូវការរាប់អានអំពីខ្ញុំ ។ ៕

ចំលងជូន:

- ខុទ្ទកាល័យក្រសួងសុខាភិបាល
- ប្រធានមន្ទីរសុខាភិបាលខេត្តពាក់ព័ន្ធ
- ប្រធានកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្តពាក់ព័ន្ធ
- ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិពាក់ព័ន្ធ
- ប្រធានមន្ទីរពេទ្យបង្អែកពាក់ព័ន្ធ
- សាមីខ្លួន
- ឯកសារ

វេជ្ជ. មាន-ឈីវុន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍
សើស្បែក និង កាមរោគ
លេខ...1362...មជអសក

រាជធានីភ្នំពេញ ថ្ងៃទី...17... ខែ...4...... ឆ្នាំ ២០...09

## សេចក្តីណែនាំស្តីពីការធ្វើរោគវិនិច្ឆ័យបន្ទាន់លើកុមារដែល ប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (Early Infant Diagnosis )

ក្រសួងសុខាភិបាលបានអនុម័តនៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ អោយចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះកុមារអាយុក្រោម១២ខែដែលមានលទ្ធផលតេស្តឈាមរកមេរោគអេដស៍ DNA-PCR បញ្ជាក់ថាវិជ្ជមានដោយពុំចាំបាច់គិតពីភាគរយនៃគ្រាប់ឈាម CD4 ។

ដើម្បីជំរុញការអនុវត្តន៏នូវអនុសាសន៏របស់ក្រសួងសុខាភិបាលខាងលើនេះអោយទទួលបានលទ្ធផលល្អនោះនិងចូលរួមចំណែកកាត់បន្ថយអាត្រាមរណ:ភាពរបស់ទារក-កុមារ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ សូមណែនាំការអនុវត្តន៏ដូចខាងក្រោមនេះ :

១-ផ្នែកព្យាបាលជំងឺឆ្លងនិងផ្នែកពិគ្រោះជំងឺនៃសេវាព្យាបាលជំងឺកុមារត្រូវលើកកំពស់ការយល់ដឹងអំពីជំងឺអេដស៏ដល់អ្នកអាណាព្យាបាលទារក-កុមារ ដែលមានជំងឺរ៉ាំរ៉ៃហើយត្រូវលើកទឹកចិត្តពួកគាត់អោយទទួលយកការធ្វើតេស្តឈាមរកមេរោគអេដស៏សំរាប់កូនគាត់ ។

២-ការធ្វើតេស្តឈាមរកមេរោគអេដស៏ត្រូវអនុវត្តតាមគោលការនិងពិធីសាររបស់ថ្នាក់ជាតិរួមមាន:

២-១ចំពោះកុមារអាយុលើសពី១៨ខែត្រូវអនុវត្តដូចពិធីសារធ្វើតេស្តរកមេរោគអេដស៏សំរាប់មនុស្សធំដែរ គឺត្រូវប្រើតេស្តរហ័ស (HIV Rapid test ) ។

២-២ ចំពោះកុមារដែលមានអាយុលើសពី ៣០ សប្តាហ៏ ( ៧ ខែ និង ១៥ ថ្ងៃ ) ត្រូវធ្វើតេស្ត DNA-PCR ដោយប្រើប្រាស់ក្រដាស់ស្ងួត ( Dried Blood Spot " DBS" ) តែមួយលើក ។ ប្រសិនបើលទ្ធផលវិជ្ជមានត្រូវជោះឈាមម្តងទៀតក្នុងរយ:ពេលមួយខែ ហើយធ្វើសំណាកឈាមផ្តិតលើ DBS មកមន្ទីរពិសោធន៏ NIPH ។

២-៣ ចំពោះកុមារអាយុក្រោម៣០ សប្តាហ៏ ( ៧ ខែ និង ១៥ ថ្ងៃ ) ត្រូវធ្វើតេស្ត DNA-PCR ដោយប្រើប្រាស់ DBS :

-លើកទី១នៅអាយុ៦ សប្តាហ៍ ( ១ខែនិង១៥ថ្ងៃ ) ប្រសិនបើលទ្ធផលតេស្តវិជ្ជមានគេត្រូវធ្វើតេស្ត DNA-PCR បញ្ជាក់ (ConfirmationTested) រយៈពេល១ខែក្រោយថ្ងៃធ្វើតេស្តលើកដំបូងដោយយកសំណាកឈាមថ្មី ។

-ចំពោះកុមារដែលមានលទ្ធផលតេស្ត DNA-PCR លើកទី១ អវិជ្ជមានត្រូវធ្វើតេស្តDNA-PCR លើកទី២នៅអាយុ ៣0 សប្តាហ៍ ( ៧ ខែ និង ១៥ ថ្ងៃ ) ។

៣-ចំពោះសេវាព្យាបាលជំងឺអេដស៍លើកុមារ (Pediatric AIDS Care) និងសេវារណបដែលចូលរួមអនុវត្តវិធីសាស្ត្រឆ្លើយតបរួមគ្នា: **អ្នកទទួលភារកិច្ចជោះឈាមដើម្បីធ្វើតេស្ត DNA-PCR លើកុមារអាយុចាប់ពី ៦សប្តាហ៍ ដល់១៨ខែ ត្រូវធ្វើការជោះឈាមលើកុមារភ្លាមៗដោយមិនចាំបាច់ធ្វើការណាត់ជួបអោយមកជោះឈាមនោះទេ ។ចំណុចសំខាន់គឺជោះឈាមនិងផ្តិតលើក្រដាស DBS អោយបានត្រឹមត្រូវតាមបច្ចេកទេសដែលបានណែនាំហើយរក្សាទុកដាក់ DBS នេះអោយបានល្អត្រឹមត្រូវដើម្បីបញ្ជូនមកមន្ទីរពិសោធន៍ NIPH ។**

៤-ក្រុមថែទាំព្យាបាលជំងឺអេដស៍លើកុមារ (Pediatric AIDS Care) **ត្រូវចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) ដល់កុមារអាយុក្រោម១ឆ្នាំដែលធ្វើ រោគវិនិច្ឆ័យមានមេរោគអេដស៍ដោយពុំចាំបាច់រង់ចាំលទ្ធផលនៃការពិនិត្យភាគរយនៃគ្រាប់ឈាម CD4 ទេ។**

ភ្នំពេញថ្ងៃទី17 ខែ វិច្ឆិកា ឆ្នាំ ២០០៩

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនិងសើស្បែក

និងកាមរោគ

វេជ្ជ ម៉ាន-ឈឺវុន

<u>ចំលងជូន :</u>

-ខុទ្ទកាល័យក្រសួងសុខាភិបាល

-អគ្គនាយកដ្ឋានបច្ចេកទេស

-នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

-មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក

-មន្ទីពេទ្យកុមារជាតិ

-មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត

-មន្ទីរសុខាភិបាលខេត្តពាក់ព័ន្ធ

-កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្តពាក់ព័ន្ធ

-មន្ទីរពេទ្យបង្អែកពាក់ព័ន្ធ

-ក្រុមថែទាំព្យាបាលជំងឺអេដស៍លើកុមារនៃមន្ទីរពេទ្យបង្អែកពាក់ព័ន្ធ

-មណ្ឌលសុខភាពដែលជាសេវារណាបដែលចូលរួមអនុវត្តវិធីសាស្រ្តឆ្លើយតបរួមគ្នា

-អង្គការសុខភាពពិភពលោក (WHO)

-អង្គការ UNICEF

-មូលនិធិគ្លិនតុន (CHAI )

-ឯកសារ

AIDS Care

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍
សើស្បែក និង កាមរោគ
លេខ...១៥១០...មជអសក

រាជធានីភ្នំពេញ ថ្ងៃទី......... ខែ......... ឆ្នាំ ២០០៩

## សេចក្តីណែនាំអំពីការបង្កើនការយកចិត្តទុកដាក់ លើកកំពស់ការយល់ដឹងរបស់អាណាព្យាបាល ឬ កុមារពីសារៈសំខាន់ក្នុងការព្យាបាលដោយឱសថ ARV អោយបានទៀងទាត់ ជាប់លាប់ និងត្រឹមត្រូវតាមវេជ្ជបញ្ជា

គិតមកដល់ត្រីមាសទី ៣ ឆ្នាំ ២០០៩ នេះ អ្នកជំងឺអេដស៍ ដែលបានទទួលការព្យាបាល ដោយឱសថប្រឆាំងមេរោគអេដស៍នៅទូទាំងប្រទេស មានប្រមាណ ៣៦០៧៧នាក់ ដែលក្នុងនោះ មានកុមារប្រមាណ ៣៤៩៩ នាក់ ។ នេះជាសមិទ្ធិផលមួយ ដែលកើតចេញពីការប្រឹងប្រែង និងរួមសហការពីគ្រប់អង្គការ និងស្ថាប័នពាក់ពន្ធ័ទាំងអស់ ជាពិសេស គឺក្រុមគ្រូពេទ្យ និងបុគ្គលិកសុខាភិបាល នៅតាមសេវាព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយឱសថ ARV (OI និង ART service) នៅទូទាំងប្រទេស ។ ទន្ទឹមនឹងនេះ ដើម្បីយល់ដឹងពីស្ថានភាពរបស់មេរោគអេដស៍ ដែលមានភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានធ្វើការអង្កេតរកមើលកត្តាផ្សេងៗ ដែលបណ្តាលអោយមានភាពស៊ាំរបស់មេរោគអេដស៍ ទៅនឹងឱសថប្រឆាំងមេរោគអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការប្រមូលសូចនាករមួយចំនួន ចាប់តាំងពីឆ្នាំ ២០០៨ ដល់ឆ្នាំ ២០០៩ នៅតាមសេវាព្យាបាល OI និង ART ចំនួន ៤១ កន្លែង ដែលក្នុងនោះ ២៥ កន្លែងមានផ្តល់សេវា ព្យាបាលជំងឺអេដស៍លើកុមារ ។

តាមរយៈការអង្កេតកន្លងមក យើងសង្កេតឃើញថា កុមារដែលមានផ្ទុកមេរោគអេដស៍ មិនបានមកទទួលការត្រួតពិនិត្យសុខភាព និងទទួលឱសថប្រឆាំងមេរោគអេដស៍ជាទៀតទាត់ទេ ដែលជាកត្តាមួយអាចប៉ះពាល់ដល់ប្រសិទ្ធភាពរបស់ឱសថប្រឆាំងមេរោគអេដស៍ ពីព្រោះមេរោគអេដស៍អាចនឹងមានភាពស៊ាំជាមួយ

ឱសថប្រឆាំងមេរោគអេដស៍ ហើយនាពេលអនាគតកុមារទាំងនោះ អាចនឹងត្រូវការ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ប្រភេទថ្មីដែលមានតំលៃកាន់តែខ្ពស់ ។

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ មានការព្រួយបារម្ភជាខ្លាំងចំពោះបញ្ហា ដែលកុមារមាន ផ្ទុកមេរោគអេដស៍មិនបានមកប្រើប្រាស់សេវា OI និង ART ដោយទៀងទាត់ ដែលជាកត្តាចំបងនាំអោយយើងធ្វើការសិក្សារកមូលហេតុ នៃបញ្ហាខាងលើនេះ តាមរយៈការវាយតំលៃជាបន្ទាន់ ។ ក្រោយពេលបញ្ចប់ការវាយតំលៃបន្ទាន់នេះ មជ្ឈមណ្ឌលជាតិ បានរកឃើញមូលហេតុមួយចំនួនដែលពាក់ពន្ធ័ នឹងភាគី អ្នកផ្តល់សេវា OI និង ART និងភាគីជាអ្នកជំងឺ និងកត្តារួមផ្សំផ្សេងៗទៀត រួមមាន ៖ ស្ថានភាពជីវភាពរបស់គ្រួសារកុមារមានភាពខ្សត់ខ្សោយ អាណាព្យាបាលមិនបានថែទាំកុមារអោយបានជិតដល់កុមារ មានទីលំនៅឆ្ងាយពីសេវា OI និង ART កង្វះថវិកាធ្វើដំណើរមកកាន់សេវា OI និង ART ការណាត់ជួបរបស់គ្រូពេទ្យមិនត្រូវ ពេលណាត់ជាមួយអាណាព្យាបាល ដែលមកទទួលការពិនិត្យនៅសេវា OI និង ART ដែរនោះ កុមារមិនបានទទួលឱសថប្រឆាំងមេរោគអេដស៍ គ្រប់ចំនួនក្នុងពេលមកកាន់សេវា OI និង ART មួយលើកៗ និង អាណាព្យាបាលកុមារមិនអាចដឹងពីថ្ងៃណាត់ ដោយសារមិនចេះមើល អក្សរ រឺ ភ្លេចថ្ងៃណាត់ដោយភាពមមាញឹកផ្សេងៗ ។

ផ្អែកលើលទ្ធផលនៃការវាយតំលៃខាងលើនេះ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ សូមធ្វើការណែនាំ ក្នុងការលើកកំពស់ការយល់ដឹងរបស់អាណាព្យាបាលកុមារ ឬ កុមារ អោយទទួលការព្យាបាលដោយ ARV បានទៀងទាត់ ជាប់លាប់ និងត្រឹមត្រូវ ដើម្បីលើកកំពស់គុណភាពជីវិតរបស់កុមារ និង កាត់បន្ថយគ្រោះថ្នាក់នៃការកកើតឡើង នូវភាពស៊ាំរបស់មេរោគអេដស៍ដូចខាងក្រោម ៖

១. លោក/លោកស្រីជាគ្រូពេទ្យព្យាបាល មេត្តាជួយសំរួលក្នុងការកំណត់ថ្ងៃណាត់ជួប ដើម្បីអោយអាណាព្យាបាលកុមារ រឺ កុមារ ដែលមានផ្ទុកមេរោគអេដស៍អាចបានមកទទួលឱសថ ARV នៅក្នុងពេលតែមួយ ។

២. លោក/លោកស្រី ដែលជាអ្នកទទួលខុសត្រូវផ្នែកឱសថស្ថានមេត្តាសំរួលអោយ កុមារបានទទួលឱសថប្រឆាំងមេរោគអេដស៍ គ្រប់ចំនួនសំរាប់ការមកពិនិត្យសុខភាពមួយលើកៗ ដើម្បីជៀសវៀងកុំអោយអ្នកជំងឺធ្វើដំណើរញឹកញាប់មកកាន់សេវា OI និង ART ដែលអាចប៉ះពាល់ដល់ជីវភាពគ្រួសាររបស់អ្នកជំងឺ ដោយត្រូវចំណាយថវិកាសំរាប់ធ្វើដំណើរច្រើន ។

៣. លោក/លោកស្រីជាគ្រូពេទ្យមេត្តាប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីអោយងាយស្រួលដឹងពីថ្ងៃណាត់របស់អាណាព្យាបាលកុមារ ឬ កុមារ ដែលត្រូវនាំកុមារ ឬ គេមកជួបគ្រូពេទ្យ តាមរយៈការអនុញ្ញាតិ អោយពួកគាត់ចូលរួមកំណត់ថ្ងៃ ដែលគាត់ត្រូវមកជួបគ្រូពេទ្យ ។

៤. លោក/លោកស្រីជាគ្រូពេទ្យ និងមន្ត្រីសុខាភិបាលពាក់ពន្ធ័ មេត្តាពន្យល់ពីការប្រើប្រាស់ឱសថ ARV អោយបានច្បាស់លាស់ ដល់អាណាព្យាបាលកុមារ ឬ កុមារផ្ទុកមេរោគអេដស៍ ។

៥. ត្រូវពង្រឹងទំនាក់ទំនងជាមួយក្រុមថែទាំតាមផ្ទះ ដោយវិធីផ្សេងៗ ដើម្បីធ្វើការរំលឹកដល់អាណាព្យាបាលកុមារ ឬ កុមារ ដែលត្រូវមកទទួលសេវា OI និង ART ជាពិសេសអោយពួកគាត់ដឹងពីថ្ងៃណាត់ជួប គ្រូពេទ្យ និង ជួយឧបត្ថម្ភដល់ពួកគាត់ អោយមកទទួលសេវា OI និង ART ដោយទៀងទាត់ តាម ការណាត់ជួបរបស់គ្រូពេទ្យ ។

ជាថ្មីម្តងទៀត មជ្ឈមណ្ឌលជាតិ សូមថ្លែងអំណរគុណ និង សំដែងការកោតសរសើរដល់គ្រប់អង្គការ និងស្ថាបន័ ពាក់ពន្ធ័ទាំងអស់ ជាពិសេស លោក/លោកស្រីជាគ្រូពេទ្យ និង បុគ្គលិកសុខាភិបាលធ្វើការនៅសេវា OI និង ART ទាំងអស់ ដែលបានយកចិត្តទុកដាក់ផ្តល់សេវាប្រកបដោយគុណភាព ជូនអ្នកជំងឺអេដស៍ ។ មជ្ឈមណ្ឌលជាតិ សូមធ្វើសេចក្តីសង្ឃឹមយ៉ាងមុតមាំ លើការចូលរួមអនុវត្តតាមការណែនាំខាងលើ ដើម្បីលើកកំពស់គុណភាពសេវាថែទាំ និងព្យាបាលអ្នកជំងឺអេដស៍អោយមាន ប្រសិទ្ធិភាពខ្ពស់ ។

វេជ្ជ. មាន_ឈីវុន

ចំលងជូន:

- ខុទ្ទកាល័យក្រសួងសុខាភិបាល
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- ការិយាល័យបច្ចេកទេសនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- ផ្នែកថែទាំ និងព្យាបាលជំងឺអេដស៍នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- គ្រប់មន្ទីរសុខាភិបាល ខេត្ត-រាជធានី
- គ្រប់ប្រធានកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ ខេត្ត-រាជធានី
- ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិពាក់ព័ន្ធ
- ប្រធានមន្ទីរពេទ្យបង្អែកពាក់ព័ន្ធ
- គ្លីនិកសុខភាពសង្គម
- មន្ទីរពេទ្យកុមារជាតិ
- មន្ទីរពេទ្យកុមារអង្គរ
- ក្រុមព្យាបាលជំងឺអេដស៍លើកុមារ (PAC Team)
- ឯកសារ